# សុន្ទរកថា

## ស្វាគមន៍ និង របាយការណ៍

## ស្តីពី

# ការជ្រើសរើសសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស ទទួលអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ សាកលវិទ្យាល័យកម្ពុជា

## ឆ្នាំសិក្សា ២០០៧ - ២០១០

<u>សូមគោរព:</u>

- សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព បណ្ឌិត Haruhisa Handa ប្រធាន អង្គការ World Mate ប្រធានមូលនិធិអន្តរជាតិ ដើម្បីសិល្បៈ និង វប្បធម៌ នៃទីក្រុងតូក្យូ - ប្រទេសជប៉ុន និងជា អធិបការបតី នៃសាកលវិទ្យាល័យកម្ពុជា
- សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ជាទីគោរព !

1- ថ្ងៃនេះ សាកលវិទ្យាល័យកម្ពុជា មានសេចក្តីសោមនស្សរីករាយ និង កិត្តិយសដ៏ឧត្តុង្គឧត្តមដោយបានរៀបចំពិធីប្រគល់ « ប័ណ្ណអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ » ជូនសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស ចំនួន ៥០០ កន្លែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

2- ក្នុងនាម សាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទសូមសម្តែងនូវសេចក្តីដឹងគុណ និង សូមស្វាគមន៍ដោយស្មោះចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ សម្តេចនាយករដ្ឋមន្ត្រី ក្នុងពិធីប្រគល់ « ប័ណ្ណអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ » ដ៏មានសារៈសំខាន់នេះ ។

3- ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោកបណ្ឌិត Haruhisa Handa និង គណៈប្រតិភូ ក៏ដូចជា ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ ដែលបានផ្តល់កិត្តិយស អញ្ជើញចូលរួមក្នុងពិធី ប្រគល់ប័ណ្ណអាហារូបករណ៍ ជាប្រវត្តិសាស្ត្រនេះ ។

4- សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីគោរព !

ប័ណ្ណអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន _ និស្សិតពូកែ គឺជាអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រទ្រង់ទ្រាយធំមួយ នៅសាកលវិទ្យាល័យកម្ពុជា សំរាប់ឆ្នាំសិក្សា ២០០៧ ~ ២០១០ ។ អាហារូបករណ៍នេះ មានចំនួន ៥០០ កន្លែង ។ គឺជា អាហារូបករណ៍ពេកថ្លៃ ១០០ % ។ សិស្សានុសិស្ស ថ្នាក់ធម្មមសិក្សាទូទាំងប្រទេស ដែលអាចដាក់ពាក្យស្នើសុំចូលប្រកួតប្រជែងយកអាហារូបករណ៍នេះបាន គឺជាសិស្សានុសិស្សថ្នាក់ទី ១២ ដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំ ២០០៦ ~ ២០០៧ និង បានទទួលនិទ្ទេស A ~ B ឬ C ក្នុងការប្រឡងនោះ ។ ចំពោះសិស្សានុសិស្សដែលបាន ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំនេះ តែពុំបានទទួលនិទ្ទេស A ~ B ឬ C នោះគេពុំអាចចូលរួមប្រកួតប្រជែងយក អាហារូបករណ៍នេះបានឡើយ ។

សាកលវិទ្យាល័យកម្ពុជា សូមសម្តែងនូវកតញ្ញូតាដ៏ខ្ពង់ខ្ពស់ចំពោះ សម្តេចនាយករដ្ឋមន្ត្រី ដែលបានអនុញ្ញាតឱ្យ សាកលវិទ្យាល័យកម្ពុជា ប្រសិទ្ធនាមអាហារូបករណ៍នេះថា « ប័ណ្ណអាហា_រូបករណ៍ជាតិ សម្តេច ហ៊ុន សែន _ និស្សិតពូកែ » តាមចំណាររអនុញ្ញាត ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៣ ។ នេះគឺជា មហាករុណាទិគុណ សម្តេចនាយក ដែលយើងខ្ញុំពុំអាចបំភ្លេចបាន ។ អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន _ និស្សិតពូកែ ឧបត្ថម្ភដោយ បណ្ឌិត Haruhisa Handa ប្រធាន អង្គការ World Mate ប្រធាន ស្ថាបនិកមូលនិធិ អន្តរជាតិដើម្បីសិល្បៈ និង វប្បធម៌ នៃប្រទេសជប៉ុន និងជា អធិបការបតី នៃសាកល វិទ្យាល័យកម្ពុជា ។ សាកលវិទ្យាល័យកម្ពុជា ក៏ដូចជាមាតាបិតា និង អាណាព្យាបាលសិស្សានុសិស្ស ដែលបានទទួលអាហារូបករណ៍នេះ សូមសម្តែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ លោកបណ្ឌិត Haruhisa Handa និង អង្គការរបស់លោក ដែលបានឧបត្ថម្ភអាហារូបករណ៍ដ៏សប្បុរសនេះ ។

5- សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីគោរព !

គោលដៅជាសក្តានុពល នៃការបង្កើតឱ្យមាន « ប័ណ្ណអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន _ និស្សិតពូកែ » គឺដើម្បី :

1)- ចូលរួមធ្វើវិភាគទានដល់ការអភិវឌ្ឍធនធនាមនុស្ស បញ្ញវន្ត នៅប្រទេសកម្ពុជា ពិសេសគឺបន្ទាប់ពី បញ្ញវន្តខ្មែរត្រូវបាត់បង់ស្ទើរតែទាំងស្រុង ក្នុងសម័យខ្មែរក្រហមប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥ - ១៩៧៩;

2)- ដើម្បីលើកស្ទួយការអប់រំថ្នាក់ឧត្តមសិក្សា បង្កើនការអភិវឌ្ឍសមត្ថភាព និង ធនធានមនុស្ស ដើម្បីជួយប្រទេសកម្ពុជា ឱ្យឆ្លើយតបបានយ៉ាងល្អប្រសើរទៅនឹងចរន្តនៃសាកលភាវូបនីយកម្ម ក៏ដូចជា ដើម្បីជួយធ្វើវិភាគទាន ឱ្យប្រទេសកម្ពុជាបានធ្វើសមាហរណកម្មពេញទំហឹងទៅក្នុងតំបន់ និង សហគមន៍អន្តរជាតិ ;

3)- អប់រំ ហ្វឹកហ្វឺន និង ត្រៀមស្ថាបនាអ្នកដឹកនាំកម្ពុជា ទៅអនាគត ;

4)- ផ្តល់នូវកាលានុវត្តភាពអប់រំកាន់តែច្រើនឡើងថែមទៀត និង ផ្តល់លទ្ធភាពឱ្យនិស្សិតដែលមកពីជនបទ និង ដែលគ្មានមធ្យោបាយសំរាប់បន្តការសិក្សា ទៅថ្នាក់ឧត្តមបានរៀនសូត្រ;

5)- រួមចំណែកកាត់បន្ថយភាពក្រីក្រ នៅប្រទេសកម្ពុជា តាមរយៈការពង្រឹងនូវកាលានុវត្តភាពអប់រំ ក៏ដូចជា ការបង្កើនឱកាសស្វែងរកការងារធ្វើ សំរាប់និស្សិតខណៈពេលដែលគេកំពុងសិក្សា និង ក្រោយពេលសិក្សារបស់គេ; និង

6)- ចូលរួមស្ថាបនា និង អភិវឌ្ឍប្រទេសកម្ពុជា ជាចីរភាព និង ការអភិវឌ្ឍសង្គមបញ្ញវន្ត ។

ដើម្បីសំរេចគោលដៅនេះ សាកលវិទ្យាល័យកម្ពុជា បានធ្វើការផ្សព្វផ្សាយ និង ជ្រើសរើសអ្នកទទួលអាហារូបករណ៍នេះ ក្នុងចំណោមបេក្ខជន ជាសិស្សានុសិស្សដែលអញ្ជើញមកពី សាលាមធ្យមសិក្សាខេត្ត - ក្រុង ចំនួន ...... នាក់ តាមរយៈការប្រឡងប្រកួតប្រជែងដោយ តម្លាភាព និង យុត្តិធម៌ នៅសាកលវិទ្យាល័យកម្ពុជា នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧ ។ សិស្សានុសិស្សដែលមានកិរិតយល់ដឹង និង សមត្ថភាពអាចទទួលយក អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន - និស្សិតពូកែ - សាកលវិទ្យាល័យកម្ពុជា ឆ្នាំ ២០០៧ - ២០១០ បានចំនួន ៥០០ នាក់ ដែលក្នុងនោះសិស្សានុសិស្សជាបុរសភេទមានចំនួន ..... នាក់ និងជា ស្ត្រីភេទមានចំនួន ..... នាក់ ។ សិស្សានុសិស្សទាំង ៥០០ នាក់នេះ អញ្ជើញមកពីខេត្ត - ក្រុងដូចខាងក្រោម :

- ខេត្ត ................. ចំនួន ......... នាក់ បុរស: ..... នាក់ ស្ត្រី: ..... នាក់
- ខេត្ត ................. ចំនួន ......... នាក់ បុរស: ..... នាក់ ស្ត្រី: ..... នាក់
- ខេត្ត ................. ចំនួន ......... នាក់ បុរស: ..... នាក់ ស្ត្រី: ..... នាក់
- ខេត្ត ................. ចំនួន ......... នាក់ បុរស: ..... នាក់ ស្ត្រី: ..... នាក់

- ខេត្ត ................. ចំនួន ......... នាក់ បុរសៈ ..... នាក់ ស្ត្រីៈ ..... នាក់
- ខេត្ត ................. ចំនួន ......... នាក់ បុរសៈ ..... នាក់ ស្ត្រីៈ ..... នាក់
- រាជធានីភ្នំពេញ ..........................................................................

**សរុបរួម ចំនួន ៥០០ នាក់**

- **សម្តេចនាយករដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**
- **ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីគោរព !**

និស្សិតអាហារូបករណ៍ ចំនួន ៥០០ នាក់នេះ នឹងទទួល « **ប័ណ្ណអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន – និស្សិតពូកែ** ពី **សម្តេចនាយករដ្ឋមន្ត្រី** ដោយផ្ទាល់នៅព្រឹកនេះ នឹងចាប់ផ្តើមចូលសិក្សា នៅសាកលវិទ្យាល័យកម្ពុជា ដើម្បីយកសញ្ញាបត្រថ្នាក់បរិញ្ញា លើមុខវិជ្ជាសំខាន់ៗមួយចំនួនចាប់តាំងពី ឆមាសទី ១ ឆ្នាំ ២០០៧ នេះរហូតដល់ ឆ្នាំ ២០១០ ។

សង្ឃឹមថា ដល់ឆ្នាំ ២០១០ ក្មួយៗទាំងអស់នឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្លួន ប្រកបដោយជោគជ័យ នឹងបានក្លាយខ្លួនជា បញ្ញវន្ត ស្ថាបនិកសង្គមថ្មីដ៏ខ្លាំងក្លា ឬ បន្តការសិក្សាទៅថ្នាក់ឧត្តមទៀត ប្រកបដោយមោទនភាព ។

ជាថ្មីម្តងទៀត នៅទីបញ្ចប់នេះ ក្នុងនាមសាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទសូមសម្តែងនូវសេចក្តីដឹងគុណដ៏ខ្ពង់ខ្ពស់ចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមជា ប្រធានគណៈអធិបតី ដ៏ខ្ពង់ខ្ពស់ក្នុងពិធី ប្រគល់ប័ណ្ណអាហារូបករណ៍នេះ ។

សូមថ្លែងអំណរគុណចំពោះ **បណ្ឌិត** Haruhisa Handa និង គណៈប្រតិភូ ដែលជាម្ចាស់អំណោយ ដ៏ដូចជា ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមជា កិត្តិយសក្នុងពិធីនេះ ; និង

សូមគោរពជូនពរ **សម្តេចនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តយសជាតិ និង អន្តរជាតិ សូមអោយបានប្រកបដោយ ជោគជ័យ សេរីមង្គល និង វិបុលសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**